Labor

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៣១៨ សកបយ.

រាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០១

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការដោះស្រាយវិវាទបុគ្គល

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកប/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សម្រេច

ប្រការ១.- ក្នុងការដោះស្រាយវិវាទបុគ្គល មុននិងប្តឹងទៅតុលាការ ភាគីណាមួយអាចប្តឹងជាលាយលក្ខណ៍អក្សរទៅអធិការការងារ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន។

នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្ថិតនៅអាគារលេខ ២៨ ផ្លូវសម្តេចព្រះធម្មលិខិតរ៉ុក ផ្លូវលេខ១៨៤ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ មានសមត្ថកិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅរាជធានីភ្នំពេញ។

មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងដទៃទៀត មានសមត្ថ

កិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅខេត្ត-ក្រុងរៀងៗខ្លួន ។

ប្រការ២.- ក្រោយពីបានទទួលបណ្តឹងពីភាគីណាមួយ អធិការការងារត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់នូវពត៌មាន និងឯកសារជាភស្តុតាងនានាដែលខ្លួនចង់បាន ដើម្បីផ្សះផ្សាវិវាទអោយបានលបស្រប ។

ការសាកសួរពត៌មានបន្ថែមនេះ ត្រូវធ្វើឡើងមួយភាគីម្តងដាច់ដោយឡែកពីគ្នា ។ គ្រប់ពេលសាកសួរពត៌មានបន្ថែម ត្រូវធ្វើកំណត់ហេតុទុកជាឯកសារដោយមានចុះហត្ថលេខាអធិការការងារ និងភាគីដែលផ្តល់ពត៌មាននោះផង ។ កំណត់ហេតុនេះត្រូវផ្តល់ជូនភាគីដែលផ្តល់ពត៌មាន ១ ច្បាប់ផង ។

ប្រការ៣.- បើភាគីដើមចោទ ឬតំណាងនៃជននេះ មិនព្រមអញ្ជើញទៅផ្តល់ពត៌មានបន្ថែមជូនអធិការការងារតាមកាលកំណត់ ឬក្នុងរយៈពេលបីថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ " គិតតែថ្ងៃធ្វើការ " ដោយគ្មានមូលហេតុសមស្របទេនោះ ពាក្យប្តឹងនោះត្រូវទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះ មិនព្រមចូលបង្ហាញខ្លួនតាមពេលកំណត់ ឬក្នុងរយៈពេលបីថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ " គិតតែថ្ងៃធ្វើការ " ដោយគ្មានមូលហេតុសមស្របទេនោះ រឿងវិវាទត្រូវចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថា ភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

ប្រការ៤.- បន្ទាប់ពីបានទទួលពត៌មានសព្វគ្រប់អស់ហើយ អធិការការងារត្រូវធ្វើលិខិតអញ្ជើញម្តងទៀតអោយភាគីទាំងសងខាងចូលរួមប្រជុំជាមួយគ្នាដើម្បីធ្វើការផ្សះផ្សា ។

អធិការការងារត្រូវធ្វើការផ្សះផ្សាវិវាទបុគ្គលក្នុងរយៈពេលបីសប្តាហ៍យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យប្តឹង ។

ភាគីវិវាទអាចអោយគេជួយអម ឬអោយគេតំណាងខ្លួនបាន ។

បើភាគីដើមចោទ ឬតំណាងនៃជននេះមិនចូលរួមប្រជុំតាមការកំណត់ ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេនោះ ពាក្យប្តឹងត្រូវចាត់ទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះ មិនចូលរួមប្រជុំតាមការកំណត់ ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេនោះ រឿងវិវាទត្រូវចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថាភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

ប្រការ៥.- លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៤ ខាងលើ ត្រូវផ្ញើជូនភាគីតាមសំបុត្រអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃ ដែលមានចុះហត្ថលេខាបញ្ជាក់ថាបានទទួលហើយ ។

ប្រការ៦.- ជនទាំងឡាយនឹងអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីវិវាទបានលុះត្រាតែជននោះជាមនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយអាចសំរេចកិច្ចការបានផង ។

ប្រការ៧.- ត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សាដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់

ព្រមសះជានិងគ្នា ។ កំណត់ហេតុនោះ ត្រូវចុះហត្ថលេខាដោយអធិការការងារព្រមទាំងហត្ថលេខារបស់ភាគីទាំងសងខាង និងត្រូវចម្លងចែកភាគីផង ។

<u>ប្រការ៨</u>.- ការព្រមព្រៀងដែលបានធ្វើនៅចំពោះមុខអធិការការងារ គឺជាការព្រមព្រៀងយកជាការបានចំពោះមុខច្បាប់ ។

<u>ប្រការ៩</u>.- ក្នុងករណីមិនសះជា ដោយរាប់ទាំងការមិនសះជាដែលមានកំណត់ក្នុងប្រការ៧ និងប្រការ៤ ខាងលើផង អធិការការងារត្រូវជំរាបទៅភាគី អំពីសិទ្ធិរបស់ភាគីដើមចោទដែលអាចធ្វើពាក្យប្តឹងជាបន្តទៅតុលាការមានសមត្ថកិច្ច ទៅតាមបែបបទដែលមានកំណត់ក្នុងច្បាប់ ។

<u>ប្រការ១០</u>.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ២២ សកបរ. ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ១៩៩៤ និងលេខ ១៤៥ សកអ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ១១</u>.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចម្លងជូន</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ